# មេរៀនទី៧១៖ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ!

## [ម៉ាកុស ១៦៖ ១- ៨]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/aj1bT040CNs

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/7pc8HXTadYI

**គោលបំណង៖** ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១១៖២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយគង់តែនឹងរស់ឡើងវិញដែរ"។*

**ចំរៀង** ( *យូធូបលីង* )៖

១.នៅរស់ https://youtu.be/NGQXTg3Uogg

២. ព្រះគ្រីស្ទទ្រង់រស់ https://youtu.be/kzg10u5bil4

៣. ទ្រង់រស់សព្វថ្ងៃ https://youtu.be/Ux9ClfRcNSw

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ឋានសួគ៌នឹងនិងឋាននរក»

១. ចែកកុមារជា២ឬ៣ក្រុមហើយក្រុមនីមួយៗត្រូវឈរជាជួរ។

២. នៅពេលដែលគ្រូ ស្រែកថា "ឋានសួគ៌" កុមារត្រូវលោតទៅខាងស្តាំ ហើយនៅពេលដែលគ្រូស្រែកថា "ឋាននរក" កុមារត្រូវលោតទៅខាងឆ្វេង។

៣.ប្រសិនបើគ្រូនៅស្រែកថា "ឋានសួគ៌" កុមារត្រូវតែបន្តលោតទៅខាងស្តាំដដែល។ ពេលខ្លះគ្រូព្យាយាមលោតបន្លំកុមារឲ្យខុសពីអ្វី ដែលគាត់បានស្រែក ដើម្បីឲ្យកុមារធ្វើខុសតាមគាត់។

៤. បន្ទាប់ពីលេងល្បែងនេះចប់ គ្រូសូមពន្យល់កុមារថា ព្រះយេស៊ូវបានសុគតសម្រាប់យើង ដូច្នេះយើងមិនត្រូវទៅឋាននរកនោះទេ។ ហើយជំនួសឲ្យការធ្លាក់ទៅឋាននរកពួកយើងបានទៅឯនគរឋានសួគ៌ជាមួយព្រះយេស៊ូវជារៀងរហូត ពីព្រោះព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ។ ព្រះយេស៊ូវមានព្រះជន្មរស់!

## ៤. ការណែនាំមេរៀន

នៅថ្ងៃសុក្រដ៏ល្អកាលពី២០០០ឆ្នាំមុន ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់យើង ត្រូវបានសុគតដោយការឆ្កាង។ វាជាការសុគតដ៏ឈឺចាប់ និងឃោរឃៅដែលធ្វើឲ្យយើងភ័យខ្លាចនៅថ្ងៃនេះ - ជាពិសេសនៅពេលយើងដឹងថាព្រះគ្រីស្ទបានសុគតជំនួសយើង។ គឺយើងទេដែលត្រូវស្លាប់ តែព្រះយេស៊ូវជាអ្នកសុគតជំនួស។ ប៉ុន្តែនៅថ្ងៃទីបី ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ទ្រង់មានជ័យជម្នះ ហើយឈ្នះលើសេចក្តីស្លាប់! តាមរយៈការសុគតរបស់ទ្រង់ ព្រះអង្គបានប្រោសលោះយើងរួចពីអំពើបាប របស់យើង។ តាមរយៈការមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបង្ហាញពីអំណាចរបស់ទ្រង់ដើម្បីសង្គ្រោះ យើងរួចពីសេចក្តីស្លាប់។ ថ្ងៃនេះ យើងនឹងរៀនអំពីរបៀបដែលយើងអាចរស់នៅជាមួយទ្រង់អស់កល្បជានិច្ច ដោយសារការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលយើងធ្វើបាប ទោសនៃអំពើបាបនោះគឺជាសេចក្តីស្លាប់។ ដោយសារយើងទាំងអស់គ្នាបាន ប្រព្រឹត្ត អំពើបាប យើងទាំងអស់គ្នាសមនឹងត្រូវស្លាប់។ ប៉ុន្តែ ព្រះយេស៊ូវមិនចង់ឲ្យយើងត្រូវស្លាប់ដោយសារ អំពើបាបរបស់យើងទេ។ ព្រះយេស៊ូវបានសុគតដើម្បីទទួលទោសចំពោះអំពើបាបដែលយើងបានប្រព្រឹត្ត។ ទ្រង់បានសុគតនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់យើង!

ព្រះគម្ពីរប្រាប់យើងថា ស្ត្រីទាំងនោះបានទៅផ្នូរនៅថ្ងៃទីបី បន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង។ ពួកគេភ្ញាក់ផ្អើលដែលបានឃើញផ្នូរនៅទទេ! បន្ទាប់មក ទេវតាមួយអង្គបានប្រាប់ពួកគេថា ព្រះយេស៊ូវ មានព្រះជន្មរស់ឡើងវិញហើយ។ ម៉ារាភ័យខ្លាចហើយមិនហ៊ានប្រាប់អ្នកណាឡើយ រហូតដល់ព្រះយេស៊ូវ បានលេចមកឲ្យនាងឃើញ។ បន្ទាប់មកនាងបានប្រាប់ពួកសិស្ស ប៉ុន្តែមានអ្នកខ្លះមិនជឿនាងទេ រហូត ដល់ព្រះយេស៊ូវបានបង្ហាញខ្លួនចំពោះមុខពួកគេ។ ពេលសិស្សរបស់ទ្រង់បានឃើញថា ព្រះយេស៊ូវមាន ព្រះជន្មរស់ឡើងវិញ ខ្លះរំភើប ខ្លះរីករាយ ខ្លះភ័យខ្លាច និងខ្លះមានអារម្មណ៍ច្របូកច្របល់។

មុនពេលព្រះយេស៊ូវសុគត ព្រះអង្គបានប្រាប់ពួកសិស្សថា ព្រះអង្គនឹងសុគត ហើយនៅថ្ងៃទីបីទ្រង់នឹងមាន ព្រះជន្មរស់ឡើងវិញ។ ទោះជាយ៉ាងណា ពួកសិស្សហាក់មិនទាន់យល់ទាំងស្រុងនៅឡើយទេ។ ពួកគេ នៅមាន ការច្របូកច្របល់បន្តិចចំពោះអ្វីដែលព្រះយេស៊ូវបានមានបន្ទូល។ ប៉ុន្តែ យើងមិនត្រូវមានការភ័ន្ត ច្រឡំទេ ព្រោះយើងមានព្រះគម្ពីរទាំងមូលសម្រាប់អាន។ ព្រះគម្ពីរប្រាប់យើងយ៉ាងច្បាស់ថា ព្រះយេស៊ូវ នឹងសុគត ហើយមានព្រះជន្មរស់ឡើងវិញ។ ហើយនោះជាអ្វីដែលបានកើតឡើង។

ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ដើម្បីបង្ហាញគ្រប់គ្នាថា ទ្រង់ជាព្រះដ៏មានឫទ្ធានុភាព និងសិរីរុងរឿង របស់យើង។ គ្មានអ្វីមានអំណាចជាងព្រះយេស៊ូវឡើយ! ដោយសារព្រះយេស៊ូវបានសុគត ហើយមាន ព្រះជន្មរស់ឡើងវិញ ទើបអំពើបាបរបស់យើងអាចត្រូវបានលើកលែងទោសឲ្យ។ យើងអាចរស់នៅជា មួយព្រះយេស៊ូវអស់កល្បជានិច្ចនៅឯនគរស្ថានសួគ៌។

ហើយទ្រង់ប្រទានសេចក្តីសង្គ្រោះដល់យើងជាអំណោយឥតគិតថ្លៃ។ យើងមិនចាំបាច់ចំណាយអ្វីសម្រាប់ ការសង្គ្រោះនោះទេ។ យើងគ្រាន់តែជឿលើព្រះយេស៊ូវ ហើយទទួលយកអំណោយនៃសេចក្តីសង្គ្រោះរបស់ ទ្រង់។ ក្រោយពីទ្រង់មានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូវបានបង្ហាញខ្លួនដល់មនុស្ស ដើម្បីឲ្យគេដឹង ថា ព្រះអង្គនៅមានព្រះជន្មរស់។ព្រះអង្គស្រឡាញ់ពួកគេខ្លាំងណាស់ ហើយទ្រង់ចង់ឱ្យពួកគេជឿលើព្រះអង្គ ។

ព្រះយេស៊ូវស្រឡាញ់អ្នកខ្លាំងណាស់។ ទ្រង់ចង់ឱ្យអ្នកជឿលើព្រះអង្គផងដែរ។ ដោយជឿថាព្រះយេស៊ូវ ជាស្តេចរបស់យើងមានព្រះជន្មរស់នៅសព្វថ្ងៃនេះ!

## ៦. សំនួរពិភាក្សា

១. តើអ្វីជាការដាក់ទោសសំរាប់អំពើបាប? *(សេចក្តីស្លាប់)*

២. តើអ្នកណាបានស្លាប់សំរាប់អំពើបាបយើង? *(ព្រះយេស៊ូវ)*

៣. តើមានអ្វីកើតឡើងបន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង? *(ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ)*

៤.តើយើងទទួលបានសេចក្តីសង្គ្រោះតាមរយៈអំណាចរបស់ព្រះយេស៊ូវដោយរបៀបណា? *(ដោយការជឿថាព្រះយេស៊ូវបានសុគតសំរាប់អំពើបាបយើង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញដើម្បីសង្គ្រោះយើង)*

៥. តើអ្នកបានសង្គ្រោះដែរឬទេ? *(សូមឲ្យកុមារឆ្លើយ)*

**៧. ល្បែងកំសាន្ត** «ដណ្ដើមដបទឹក»

១. ឲ្យកុមារចាប់ដៃគូរ២នាក់ៗ

២. ចែកដបទឹកឲ្យក្រុមនីមួយៗ

៣ ឲ្យក្រុមនីមួយៗឈរជាជួរទល់មុខគ្នា ហើយដាក់ដបទឹកនៅចំកណ្ដាល។

៤. នៅពេលដែលគ្រូស្រែកថា "១ ២ ៣ ទៅ!" ពួកគេត្រូវរត់ទៅដណ្ដើមដបទឹកពីដៃគូរបស់ពួកគេ។

៥. អ្នកដែលអាចដណ្ដើមដបទឹកបានមុនគេ គឺជាអ្នកឈ្នះ។

៦. នៅពេលលេងល្បែងនេះចប់សូមពន្យល់កុមារថា ជីវិតរបស់យើងប្រៀបបីដូចជាដបទឹកអីចឹង សាតាំងតែងតែព្យាយាមឆក់យកយើងពីព្រះ។ ប៉ុន្តែព្រះយេស៊ូវបានសុគតដើម្បីលោះយើងពីអំពើបាបនិងសេចក្ដីស្លាប់ ដូច្នេះ យើងអាចរស់នៅជាមួយទ្រង់នៅឯនគរស្ថានសួគ៌អស់កល្បជានិច្ច គឺដល់អស់អ្នកដែលជឿដល់ព្រះនាមទ្រង់។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ១១៖២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយគង់តែនឹងរស់ឡើងវិញដែរ"*។

**៩. ហាត្ថកម្ម**

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពឯកសារទំព័រខាងក្រោម ខ្មៅដៃពណ៌ និងកន្ត្រៃ




១. បោះពុម្ព និងចែកឲ្យកុមារម្នាក់១សន្លឹក។

២. កុមារគួរកាត់ចេញជារាង៣ ហើយផាត់ពណ៌ និងគូរជារង្វង់លើរូបដែលមានព្រះយេស៊ូវ។

៣.យករូបព្រះយេស៊ូវដែលបានកាត់ហើយនោះ ទៅបិទពីក្រោយរូបផ្នូរ។

៤. យករូបដុំថ្មទៅបិទខាងលើ ឬចំហៀងរូបផ្នូរដើម្បីបង្ហាញថាផ្នូររបើក ដែលមានរូបព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនៅខាងក្នុង (អាចប្រើម្ជុលសម្រាប់ដេរខោអាវមកដេរភ្ជាប់ក៏បាន)។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
យើងមិនបំរើអ្នកដឹកនាំដែលបានស្លាប់ហើយដូចសាសនាផ្សេងៗនោះទេ។ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ! ដោយសារទ្រង់រស់ យើងគ្រប់គ្នាអាចធ្វើឲ្យទំនាក់ទំនងយើងរីកចំរើន និងមានមិត្តភាពល្អជាមួយនឹងព្រះ! សូមពិចារណាថា តើអ្នកអាចនឹងអរព្រះគុណទ្រង់សំរាប់អំណោយដែលមិនអាចពិព៌ណនាបាន និងអំណាចនៃការមានព្រះជន្មរស់ឡើងវិញដោយរបៀបណា? សូមធ្វើឲ្យថ្ងៃនៃបុណ្យព្រះអង្គមានព្រះជន្មរស់ជាថ្ងៃដ៏ពិសេស។ សូមយកចិត្តទុកដាក់ចំពោះអំណោយដ៏ពិតសំរាប់បុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ៖ ជីវិតថ្មីតាមរយៈការសុគត និងមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ។ ហើយសុំកុំឲ្យយើងមានការខ្មាសអៀនក្នុងការប្រាប់អ្នកដទៃថា"ទ្រង់មានព្រះជន្មរស់ឡើង វិញ!"

# ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ!







